## ទីកន្លែងសម្រាប់ចាក់ថ្នាំបង្ការរោគ

ការចាក់ថ្នាំបង្ការរោគមានផ្តល់ជូនដោយៈ

- គ្រូពេទ្យព្យាបាលជម្ងឺទូទៅ
- សាលាក្រុងមួយចំនួន
- មជ្ឈមណ្ឌលសុខភាពសហគមន៍មួយចំនួន

ប្រសិនបើលោកអ្នកពុំដឹងច្បាស់អំពីកិច្ចបំរើអ្វីខ្លះដែលមានផ្តល់ជូននៅតំបន់របស់លោកអ្នក លោកអ្នកអាចទាក់ទងជាមួយ **អង្គភាពសុខភាពសាធារណៈដែលនៅជិតលោកអ្នកជាងគេ តាមទូរស័ព្ទលេខ 1300 066 055**





SAVE THE DATE TO VACCINATE



សូមទាញយកប្រូ្វក្រាមប្រើតាមទូរស័ព្ទ APP...

ANDROID

IPHONE

ចំពោះពត៌មានបន្ថែមអំពីការចាក់ថ្នាំបង្ការរោគ សូមបើកមើលវិបសាយ **immunisation.health.nsw.gov.au** ហើយកត់ចំណាំថ្ងៃខែដើម្បីចាក់ថ្នាំបង្ការរោគ ដោយទាញយកប្រូ្វក្រាមដែលងាយស្រួលប្រើ SAVE THE DATE សម្រាប់ប្រើតាមទូរស័ព្ទដៃ Phone App ឬបោះពុម្ពគំរោងពេលចាក់ថ្នាំដែលមានលក្ខណៈផ្ទាល់ខ្លួនមួយ។

NSW GOVERNMENT | Health

SHPN (SRC) 130053

KHMER

# សូមចាក់ថ្នាំបង្ការរោគដោយកុំបង្អង់យូរ ដើម្បីជួយកុំឲ្យជម្ងឺមកក្បែរ

SAVE THE DATE TO VACCINATE



NSW GOVERNMENT | Health

## ហេតុការណ៍ទាំងឡាយ

ការចាក់ថ្នាំបង្ការរោគផ្តល់នូវកិច្ចការពារដ៏ល្អបំផុត ប្រសិនបើការចាក់ថ្នាំទាំងនេះបានបំពេញសព្វគ្រប់ទាន់ពេល។ ការពន្យារពេលចាក់ថ្នាំបង្ការរោគនៅពេលកូនតូចរបស់លោកអ្នកពុំស្រួលខ្លួន គឺជាការឆ្លើយតបធម្មតាទេ។ ក៏ប៉ុន្តែការពិតគឺថាទោះបីជាជាគេហៀរសំបោរ ឬគ្រុនផ្តាសាយបន្តិចបន្តួចក្តី ក៏គេនៅតែអាចទទួលការចាក់ថ្នាំរបស់គេបានដែរ។ ការចាក់ថ្នាំបង្ការរោគបានទាន់ពេល គឺជាវិធីល្អបំផុតដើម្បីការពារកូនរបស់លោកអ្នកកុំឲ្យកើតជម្ងឺធ្ងន់ធ្ងរ។






## ហេតុអ្វីបានជាត្រូវចាក់ថ្នាំបង្ការរោគ

- ការចាក់ថ្នាំបង្ការរោគ គឺជាវិធីល្អបំផុតដើម្បីការពារកូនរបស់លោកអ្នកកុំឲ្យកើតជម្ងឺធ្ងន់ធ្ងរ
- ដោយការចាក់ថ្នាំបង្ការរោគ លោកអ្នកកំពុងការពារកូនរបស់លោកអ្នក ក៏ដូចជាកំពុងការពារសហគមន៍ដ៏ធំទូលាយដែរ
- ពេលណាចំនួនមនុស្សចាក់ថ្នាំបង្ការរោគឲ្យកូនរបស់គេមានកាន់តែច្រើន សមត្ថភាពរបស់យើងក៏មានកាន់តែច្រើនដែរ ដើម្បីគ្រប់គ្រងជម្ងឺធ្ងន់ធ្ងរដែលអាចការពារបានដោយការចាក់ថ្នាំបង្ការរោគ។

## តើត្រូវចាក់ថ្នាំបង្ការរោគនៅពេលណា

គំរោងពេលនៃការចាក់ថ្នាំបង្ការរោគរដ្ឋញូវសៅវែលបានណែនាំថាកូនក្មេងត្រូវចាក់ថ្នាំបង្ការរោគនៅពេលគេមានអាយុដូចតទៅនេះ:

- នៅពេលកើតមក
- ៦-៨អាទិត្យ
- ៤ខែ
- ៦ខែ
- ១២ខែ
- ១៨ខែ
- ៣ឆ្នាំកន្លះ-៤ឆ្នាំ

គឺជាការសំខាន់ដែលត្រូវចាក់ថ្នាំបង្ការរោគឲ្យកូនរបស់លោកអ្នកបានទាន់ពេល។ ដោយហេតុនេះហើយ ត្រូវកំណត់ពេលទុកជាមុន ធ្វើការណាត់ជួបជាមួយវេជ្ជបណ្ឌិត ឬអ្នកផ្តល់កិច្ចបំរើចាក់ថ្នាំបង្ការរោគរបស់លោកអ្នក និងកត់ចំណាំថ្ងៃខែទុកដើម្បីចាក់ថ្នាំបង្ការរោគ។

សូមទាញយកប្រូក្រាមដែលងាយស្រួលប្រើ SAVE THE DATE សម្រាប់ប្រើតាមទូរស័ព្ទដៃ Phone App ឬបោះពុម្ពគំរោងពេលចាក់ថ្នាំដែលមានលក្ខណៈផ្ទាល់ខ្លួនមួយ ចេញពីវ៉ិបសាយ **immunisation.health.nsw.gov.au**

## ផលវិបាកបន្ទាប់បន្សំ

ថ្នាំចាក់ការពាររោគមានសុវត្ថិភាព និងប្រសិទ្ធិភាព។ គុណប្រយោជន៍នៃការចាក់ថ្នាំបង្ការរោគមានសារៈសំខាន់ច្រើន ជាងគ្រោះថ្នាក់ទាំងឡាយកើតមានពីការចាក់ថ្នាំ។ ទោះជាយ៉ាងនេះក្តី ដូចថ្នាំពេទ្យដទៃទៀតដែរថ្នាំចាក់ការពាររោគជួនកាលអាចបណ្តាលឲ្យកើតមានផលវិបាកបន្ទាប់បន្សំ។ ផលវិបាកបន្ទាប់បន្សំទាំងនេះតាមធម្មតាពុំធ្ងន់ធ្ងរឡើយ និងមានរយៈពេលខ្លីហើយទាក់ទិននឹងការឈឺចាប់ ការហើម និងការឡើងក្រហមនៅត្រង់កន្លែងចាក់ថ្នាំ។ ផលវិបាកធ្ងន់ធ្ងរកម្រកើតមានណាស់។

ប្រសិនបើលោកអ្នកមានកង្វល់ណាមួយអំពីផលវិបាកបន្ទាប់បន្សំដែលអាចកើតមាន សូមនិយាយជាមួយវេជ្ជបណ្ឌិត **ឬអ្នកផ្តល់កិច្ចបំរើចាក់ថ្នាំបង្ការរោគរបស់លោកអ្នក។**



## ការរក្សាទុកកំណត់ត្រា

លោកអ្នកនឹងត្រូវការផ្តល់នូវកំណត់ត្រានៃការចាក់ថ្នាំបង្ការរោគរបស់កូនលោកអ្នកទៅកន្លែងថែទាំកុមារ សាលាមត្តេយ្យ និងសម្រាប់ការចុះឈ្មោះចូលរៀន។ សូមទាក់ទងជាមួយកន្លែងចុះបញ្ជីចាក់ថ្នាំបង្ការរោគ តាមទូរស័ព្ទលេខ 1800 653 809 ដើម្បីទទួលយកសេចក្តីថ្លែងអំពីប្រវត្តិនៃការចាក់ថ្នាំបង្ការរោគ។

